ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
COUNCIL FOR THE DEVELOPMENT OF CAMBODIA

# សុន្ទរកថា
# ឯកឧត្តម ស៊ុន ចាន់ថុល
# ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
# តំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត
# នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
# ថ្លែងក្នុង

ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារក្រសួងធនធានទឹក
និងឧតុនិយម គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និងអាជ្ញាធរទន្លេសាប
ប្រចាំឆ្នាំ២០២៤ និងទិសដៅអនុវត្តឆ្នាំ២០២៥

ថ្ងៃព្រហស្បតិ៍ ១រោច ខែមាឃ ឆ្នាំរោង ឆស័ក ពុទ្ធសករាជ ២៥៦៨
ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៥ សណ្ឋាគារសុខាភ្នំពេញ

*- **ឯកឧត្តម ថោ ជេដ្ឋា** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និងជាប្រធានអាជ្ញាធរទន្លេសាប*
*-ឯកឧត្តម លោកជំទាវ តំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ តំណាងអង្គទូត ដៃគូអភិវឌ្ឍន៍ លោក លោកស្រី សមាជិក និងសមាជិកា នៃអង្គពិធីជាទីមេត្រី*

ថ្ងៃនេះ ខ្ញុំពិតជាមានកិត្តិយសដ៏ឧត្តុង្គឧត្តម និងសេចក្តីសោមនស្សរីករាយក្រៃលែង ដោយបានទទួលបុព្វសិទ្ធិដ៏ខ្ពង់ខ្ពស់បំផុតពី **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ធ្វើជាអធិបតីក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារក្រសួងធនធានទឹក និងឧតុនិយម គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និងអាជ្ញាធរទន្លេសាប ប្រចាំឆ្នាំ២០២៤ និងទិសដៅអនុវត្តឆ្នាំ២០២៥។

ក្នុងឱកាសដ៏ប្រពៃនេះ ខ្ញុំសូមពាំនាំនូវការផ្ដាំផ្ញើសួរសុខទុក្ខ និងក្ដីស្រឡាញ់ដ៏ជ្រាលជ្រៅពី **សម្ដេចធិបតីនាយករដ្ឋមន្ត្រី** ជូនដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់ នៃក្រសួងធនធានទឹក និងឧតុនិយម គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និងអាជ្ញាធរទន្លេសាប។

ការពិនិត្យ ការតាមដាន និងការវាយតម្លៃលទ្ធផលការងារ ដែលសម្រេចបានក្នុងឆ្នាំកន្លងទៅ ព្រមទាំងការលើកទិសដៅការងារឆ្នាំបន្ទាប់ គឺជាកិច្ចការចាំបាច់បំផុតរបស់ក្រសួងស្ថាប័ននីមួយៗត្រូវអនុវត្តដើម្បីចូលរួមអនុវត្តក្របខណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល។

ខ្ញុំបានស្ដាប់ដោយយកចិត្តទុកដាក់ នូវសេចក្ដីរាយការណ៍យ៉ាងពិស្ដារមុននេះរបស់ឯកឧត្តម **ថោ ជេដ្ឋា** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និងជាប្រធានអាជ្ញាធរទន្លេសាប។ តាំងនាមឱ្យ **សម្ដេចធិបតីនាយករដ្ឋមន្ត្រី** និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្ដែងនូវការអបអរសាទរ កោតសរសើរ និងការវាយតម្លៃខ្ពស់ចំពោះលទ្ធផល ដែលក្រសួង-ស្ថាប័នទាំង៣ សម្រេចបាននាពេលកន្លងមក ដើម្បីជំរុញកម្ពុជាឆ្ពោះទៅ «ជាប្រទេសមួយ ដែលធានាបាននូវសន្តិសុខទឹក ទាំងបរិមាណ និងគុណភាព សម្រាប់ចូលរួមចំណែកដល់ការអភិវឌ្ឍលើគ្រប់វិស័យ»។

ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួង-ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមក្នុងពិធីបិទសន្និបាតនេះ និងសូមសម្ដែងនូវការកោតសរសើរចំពោះ ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួង-ស្ថាប័នទាំង៣ ដែលបានរួមគ្នាអស់ពីកម្លាំងកាយចិត្ត និងប្រាជ្ញា ស្មារតី ក្នុងការបំពេញភារកិច្ច ប្រកបដោយសាមគ្គីភាព ការទទួលខុសត្រូវខ្ពស់ និងសម្រេចបានលទ្ធផលគួរជាទីមោទនៈ សម្រាប់ជាឧត្តមប្រយោជន៍ជូនជាតិ និងប្រជាជន លើការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍធនធានទឹក និងឧតុនិយម ព្រមទាំងធនធានដទៃទៀតដែលពាក់ព័ន្ធនឹងទឹក។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី!*

ក្នុងរយៈពេលជិត៣ទសវត្សរ៍ចុងក្រោយនេះ ក្រោមម្លប់ដ៏ត្រជាក់ នៃសុខសន្តិភាព ពេញផ្ទៃប្រទេស តាមរយៈនយោបាយឈ្នះ-ឈ្នះរបស់ **សម្តេចតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រី និងបច្ចុប្បន្នជាប្រធានព្រឹទ្ធសភាកម្ពុជា សម្រេចបាននូវសមិទ្ធផលដ៏ធំធេងលើគ្រប់វិស័យ ទាំងនយោបាយ សង្គម និងសេដ្ឋកិច្ច ដែលនាំឱ្យកម្ពុជាមានការផ្លាស់ប្តូរមុខមាត់ថ្មី គួរជាទីមោទនៈបំផុតទាំងនៅក្នុងតំបន់ និងនៅលើឆាកអន្តរជាតិ។

លើមូលដ្ឋាននេះ និងផ្អែកតាមកម្មវិធីនយោបាយរបស់ខ្លួន រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងឈ្លាសវៃ ប្រកបដោយចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដើម្បី **កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព** តាមរយៈការអនុវត្តអភិក្រម «**ផ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់**»។ យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ បានកំណត់យកអាទិភាពគន្លឹះ៥ គឺ «**មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា**» ជាការឆ្លើយតបទៅនឹងតម្រូវការក្នុងការលើកកម្ពស់ផលិតភាពសេដ្ឋកិច្ច ដែលជាគ្រឹះ និងមធ្យោបាយសំខាន់ក្នុងការសម្រេចបាននូវចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ សំដៅប្រែក្លាយកម្ពុជាទៅជាប្រទេសមានចំណូលខ្ពស់។ ជាក់ស្តែង គិតមកដល់បច្ចុប្បន្ននេះ គម្រោងធំៗជាច្រើនត្រូវបានលេចចេញជារូបរាងដូចជា៖ ផ្លូវល្បឿនលឿនភ្នំពេញ-ក្រុងព្រះសីហនុ, អាកាសយានដ្ឋានអន្តរជាតិសៀមរាប-អង្គរ, អាកាសយានដ្ឋានអន្តរជាតិតេជោក្រុងតាខ្មៅ, តំបន់សេដ្ឋកិច្ចពិសេសខេត្តព្រះសីហនុ, និងផ្លូវល្បឿនលឿនភ្នំពេញ-ក្រុងបាវិត ក៏បាននិងកំពុងដំណើរការសាងសង់ដែលនឹងលេចរូបរាងឡើងក្នុងពេលអនាគតផងដែរ។

ជាមួយនឹងការដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ រាជរដ្ឋាភិបាលអាណត្តិទី៧ គម្រោងវិនិយោគធំៗជាច្រើនបន្ថែមទៀត បាននិងកំពុងត្រៀមអនុវត្តជាពិសេស គម្រោងព្រែកជីកហ្វូណនតេជោ ដែលជាគម្រោងប្រវត្តិសាស្ត្រ កើតចេញពីគំនិតផ្តួចផ្តើមរបស់ **សម្តេចតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រី នៃព្រះរាជាណា-

ចក្រកម្ពុជា ដែល **សម្តេចតេជោ** បានគាំទ្រយ៉ាងពេញទំហឹងលើការសិក្សារហូតទទួលបានការអនុម័តឱ្យអនុវត្តគម្រោងនេះ ក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៣។ គម្រោងប្រវត្តិសាស្ត្រនេះ បានប្រកាសបើកការដ្ឋានសាងសង់នៅថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៤ កន្លងទៅ ដែលទទួលបានការសាទរយ៉ាងក្លៀវក្លាពីប្រជាពលរដ្ឋខ្មែរយើងគ្រប់មជ្ឈដ្ឋាន នឹងគ្រោងបញ្ចប់ការសាងសង់ទៅតាមការគ្រោងទុកនៅមុនឆ្នាំ២០២៨។ បន្ទាប់ពីព្រែកជីកហ្វូណនតេជោសាងសង់រួច ព្រែកជីកនេះនឹងផ្តល់អត្ថប្រយោជន៍ដ៏មហាសាលដល់សង្គម-សេដ្ឋកិច្ចកម្ពុជា ជាពិសេស ជួយកាត់បន្ថយផលប៉ះពាល់ពីគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតជាអតិបរមាសម្រាប់ខេត្តភាគខាងកើត និងភាគនិរតីរបស់កម្ពុជា។

ស្របជាមួយគ្នានេះ យើងខ្ញុំនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ក.អ.ក.) ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល លើការងារវិនិយោគ ដែលមាន **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ជាប្រធាន ក.អ.ក. បានបន្តខិតខំជំរុញការកែលម្អ និងធ្វើឱ្យប្រសើរឡើងនូវបរិយាកាសធុរកិច្ច និងវិនិយោគ តាមរយៈការជំរុញផ្សព្វផ្សាយនូវច្បាប់ស្តីពីវិនិយោគ ការគោះទ្វារវិនិយោគនៅក្រៅប្រទេស ព្រមទាំងការសម្រួល និងធ្វើសាមញ្ញកម្មនីតិវិធីពាក់ព័ន្ធនានា ជាពិសេស ការធ្វើឌីជីថលភាវូបនីយកម្មសម្រាប់ការផ្តល់សេវាសាធារណៈ។ ជាមួយគ្នានេះ កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២៤ កន្លងទៅ ក.អ.ក. បានសម្ពោធដាក់ឱ្យប្រើប្រាស់ជាសាធារណៈនូវប្រព័ន្ធគ្រប់គ្រងគម្រោងវិនិយោគកម្ពុជា (CDC Investment Project Management -cdcIPM) ដែលជាថ្នាលបច្ចេកវិទ្យា សម្រាប់អនុញ្ញាតឱ្យវិនិយោគិនអាចដាក់ពាក្យស្នើសុំចុះបញ្ជីគម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ តាមប្រព័ន្ធអនឡាញបានពីគ្រប់ទីកន្លែង ទាំងការដាក់ពាក្យ ការបង់កម្រៃសេវា និងការទទួលបាននូវវិញ្ញាបនបត្រចុះបញ្ជីគម្រោងជាទម្រង់ឌីជីថលផងដែរ និងឈានទៅដល់ការតភ្ជាប់ជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធនាពេលខាងមុខ។

ខ្ញុំសូមជម្រាបជូនអង្គពិធីទាំងមូលជ្រាបថា នៅក្នុងឆ្នាំ២០២៤ ក.អ.ក. តាមរយៈគណៈកម្មាធិការវិនិយោគកម្ពុជា (គ.វ.ក.) បានអនុម័តគម្រោងវិនិយោគទាំងក្នុង និងក្រៅតំបន់សេដ្ឋកិច្ចពិសេស សរុបចំនួន ៤១៤ គម្រោង ក្នុងទុនវិនិយោគសរុបប្រមាណ

៦,៩ ប៊ីលាន ដុល្លារអាម៉េរិក។ បើប្រៀបធៀបនឹងឆ្នាំ២០២៣ ចំនួនគម្រោងវិនិយោគមានចំនួន ២៦៨ គម្រោង កើនឡើងចំនួន ១៤៦គម្រោង ស្មើនឹងប្រមាណ ៥៤% រីឯទុនវិនិយោគមានការកើនឡើងប្រមាណជិត ២ ពាន់លាន ដុល្លារអាម៉េរិក ស្មើនឹងប្រមាណ ៤០%។ នេះជាលើកទី១ហើយ ដែល ក.អ.ក. បានធ្វើការអនុម័តចំនួនគម្រោងវិនិយោគក្នុងរយៈពេល ១ឆ្នាំ រហូតដល់ទៅជាង ៤០០ គម្រោង។

តួលេខនៃការកើនឡើងនៃគម្រោងវិនិយោគនេះ បង្ហាញឱ្យឃើញពីការជឿទុកចិត្តរបស់វិនិយោគិនមកលើរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** រួមជាមួយនឹងកត្តាសំខាន់ៗដូចជា៖ (១) កត្តាសុខសន្តិភាព ស្ថេរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ច (២) លក្ខខណ្ឌល្អប្រសើរនៃក្របខណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត និង (៣) ការបើកចំហសេដ្ឋកិច្ចទទួលការវិនិយោគស្ទើរលើគ្រប់វិស័យ ជាពិសេស ភាពអំណោយផលនៃលក្ខខណ្ឌ និងការលើកទឹកចិត្តវិនិយោគ ដូចមានចែងក្នុងច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា។

***ឯកឧត្តម លោកជំទាវ លោក លោកស្រី!***

ជាការពិត ទឹកគឺជាធនធានដ៏មានសារៈសំខាន់សម្រាប់ទ្រទ្រង់ភាវៈមានជីវិតទាំងអស់ និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ក៏ប៉ុន្តែធនធានទាំងនេះកាន់តែខ្សត់ទៅៗពីមួយថ្ងៃទៅមួយថ្ងៃ ដោយសារសកម្មភាពអវិជ្ជមានមួយចំនួនរបស់មនុស្សដែលបានធ្វើឱ្យប៉ះពាល់ដល់ប្រភពទឹក និងគុណភាពទឹក។ កត្តាទាំងនោះរួមមាន ការប្រែប្រួលអាកាសធាតុដែលបណ្តាលឱ្យកើតមាននូវគ្រោះទឹកជំនន់ និងភាពរាំងស្ងួតញឹកញាប់ជាងមុន ការកើនឡើងនូវចំនួនប្រជាជន និងការរីកចម្រើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស ដែលបាន និងកំពុងបន្តដាក់សម្ពាធយ៉ាងខ្លាំងដល់ធនធានទឹក និងប្រព័ន្ធអេកូឡូស៊ី។

ធនធានទឹក ជាចំណុចស្នូល នៃវិស័យកសិកម្ម ឧស្សាហកម្ម និងទឹកស្អាត ដែលនៅតែជាវិស័យចម្បងសម្រាប់ប្រទេសកម្ពុជា ក្នុងការរក្សាស្ថិរភាពតម្លៃស្បៀង ធានាសន្តិសុខស្បៀង និងជីវភាពរស់នៅ របស់ប្រជាពលរដ្ឋ។ តាមការស្រាវជ្រាវដោយធនាគារពិភពលោក

ថ្មីៗនេះ បានគូសបញ្ជាក់ថារាល់ការវិនិយោគ ១ដុល្លារ លើការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ អាចបង្កើតបានផលចំណេញផ្នែកសេដ្ឋកិច្ចរហូតដល់ ៤ដុល្លារ។ ជាមួយនឹងកិច្ចប្រឹងប្រែង យ៉ាងសកម្ម និងប្រកបដោយភាពបុរេសកម្មរបស់វិស័យធនធានទឹក រួមជាមួយវិស័យដទៃទៀតបានជួយឱ្យកម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ច រង្វង់ប្រមាណ ៦% នៅឆ្នាំ២០២៤ និងត្រូវបានព្យាករណ៍ថានឹងបន្តកើនឡើងក្នុងរង្វង់ប្រមាណ ៦,៣% នៅឆ្នាំ២០២៥។

ដូច្នេះ កម្ពុជាចាត់ទុកទឹកជា "**មាស ស**" ដែលជាកម្លាំងចលករសម្រាប់ជំរុញការអភិវឌ្ឍ និងវឌ្ឍនភាពសេដ្ឋកិច្ច-សង្គម ប្រកបដោយចីរភាព និងបរិយាប័ន្ន។ រាជរដ្ឋាភិបាលកម្ពុជា តែងតែទទួលស្គាល់អំពីសារសំខាន់ជាយុទ្ធសាស្ត្រ និងផ្តល់អាទិភាពខ្ពស់ចំពោះវិស័យធនធានទឹក តាមរយៈការជំរុញការគ្រប់គ្រងធនធានទឹកឱ្យកាន់តែប្រសើរ ដើម្បីធានាបាននូវសន្តិសុខទឹកក្នុងក្របខណ្ឌទូទាំងប្រទេស ដោយបន្តកិច្ចសហការជាមួយគ្រប់ភាគីពាក់ព័ន្ធក្រោមយន្តការតំបន់ និងសកល ដើម្បីពង្រឹងនិងលើកកម្ពស់អភិបាលកិច្ច និងការគ្រប់គ្រងធនធានទឹក និងអាងទន្លេឆ្លងដែន ឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ក្នុងការឈានទៅសម្រេចនូវគោលដៅ "**ទឹកដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាព**"។

ក្នុងន័យនេះ ខ្ញុំមានជំនឿយ៉ាងមុតមាំថា តាមរយៈឆន្ទៈនយោបាយកម្រិតខ្ពស់ ការខិតខំប្រឹងប្រែង និងការធ្វើសកម្មភាពរួមគ្នារបស់ស្ថាប័នទាំងបី នឹងរួមចំណែកដល់ការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ និងធានាបាននូវជោគជ័យដល់ការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀត ប្រកបដោយនិរន្តរភាព និងបរិយាប័ន្ន។

***- ឯកឧត្តម លោកជំទាវ លោក លោកស្រី!***

ជាមួយនឹងសមិទ្ធផលដែលសម្រេចបាន និងទិសដៅការងារដែលបានដាក់ចេញសម្រាប់ឆ្នាំ២០២៥ ខ្ញុំសូមផ្តល់អនុសាសន៍បន្ថែមមួយចំនួនជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃស្ថាប័នទាំង៣ ព្រមទាំងក្រសួង-ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ផ្តោតការយកចិត្តទុកដាក់លើការងារជាក់ស្តែងមួយចំនួន ដូចខាងក្រោម៖

ទី១៖ បន្តពង្រឹងអភិបាលកិច្ចស្ថាប័ន ដោយកសាង និងលើកកម្ពស់មូលធនមនុស្ស តាមរយៈ ការពង្រឹងសមត្ថភាពបច្ចេកទេស ការប្រើប្រាស់បច្ចេកវិទ្យាទំនើប ការលើកទឹកចិត្ត ការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយគ្រប់ភាគីពាក់ព័ន្ធ និងការបញ្ជ្រាបយេនឌ័រ សំដៅដល់ការពង្រឹងការគ្រប់គ្រងធនធានទឹក តាមអាងទន្លេ និងអាងស្ទឹង ដោយឈរលើគោលការណ៍គ្រប់គ្រងធនធានទឹកចម្រុះ

ទី២៖ ក្រសួងធនធានទឹក និងឧតុនិយម ត្រូវពន្លឿនការរៀបចំនីតិវិធី និងស្នើសុំអនុម័ត អនុក្រឹត្យស្តីពីអាផ្សាបណ្ណទឹក អនុក្រឹត្យស្តីពីគុណភាពទឹក និងបទបញ្ញត្តិនានា ដែលចាំបាច់ ដើម្បីអនុវត្តភារកិច្ច និងការទទួលខុសត្រូវរបស់ក្រសួង

ទី៣៖ ក្រសួងធនធានទឹក និងឧតុនិយម និងអាជ្ញាធរទន្លេសាប ត្រូវបន្តអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន ដោយសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋានគ្រប់រាជធានី-ខេត្ត ក្នុងការពន្លឿនការចុះបញ្ជីផ្ទៃដីអាង ការទប់ស្កាត់ការកាប់បំផ្លាញព្រៃលិចទឹកក្នុងតំបន់៣ នៅជុំវិញបឹងទន្លេសាប និងជម្រុញបញ្ចប់ការធ្វើបច្ចុប្បន្នភាពផែនទីតំបន់១ តំបន់២ និងតំបន់៣ នៃតំបន់ទន្លេសាប និងធ្វើការបោះបង្គោលព្រំ ព្រមទាំងការទប់ស្កាត់រាល់ការទន្ទ្រានកាន់កាប់ដីក្នុងអាងស្តុកទឹក ដីព្រៃលិចទឹក ការចាក់ដី និងថ្មចូលក្នុង ទន្លេ ស្ទឹង អូរ និងបឹងបួរ នៅទូទាំងប្រទេស ព្រមទាំងជម្រុញការរៀបចំផែនទីបង្ហាញផ្លូវយុទ្ធសាស្ត្រ សម្រាប់ការគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់ទន្លេសាបប្រកបដោយចីរភាព

ទី៤៖ សហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីសិក្សាពីការប្រើប្រាស់ទឹកស្អាត បរិមាណទឹក តាមអាងស្តុកទឹក និងប្រភពទឹកនានា រួមទាំងទឹកក្រោមដី ដើម្បីបម្រើឱ្យការប្រើប្រាស់ ការស្រោចស្រព និងការការពារប្រព័ន្ធអេកូឡូស៊ី

ទី៥៖ ពង្រឹងសមត្ថភាពការផ្តល់សេវាឧតុនិយម ដោយបំពាក់ឧបករណ៍បច្ចេកទេសទំនើបបន្ថែម ដើម្បីអាចធានាបាននូវការព្យាករណ៍ដែលមានសុក្រឹត្យភាព និងជឿទុកចិត្តបានសម្រាប់បម្រើដល់វិស័យពាក់ព័ន្ធដូចជា៖ កសិកម្ម ទឹកស្អាត អាកាសចរណ៍ស៊ីវិល នាវាចរណ៍ និងការគ្រប់គ្រងគ្រោះមហន្តរាយ

ទី៦៖ បន្តអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនដោយសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋានគ្រប់រាជធានី-ខេត្ត ដើម្បីទប់ស្កាត់ និងកាត់បន្ថយគ្រោះមហន្តរាយបង្កឡើងដោយ ធម្មជាតិ ដូចជា៖ ទឹកជំនន់ និងគ្រោះរាំងស្ងួត តាមរយៈការ

កសាងហេដ្ឋារចនាសម្ព័ន្ធការងារទឹកប្រកបដោយគុណភាព និងការពង្រឹងប្រសិទ្ធភាពព្យាករណ៍ទឹកជំនន់ និងធាតុអាកាស

ទី៧៖ បន្តប្រែក្លាយសក្តានុពលប្រភពផ្គត់ផ្គង់ទឹក តាមរយៈការកសាងទំនប់អាងស្តុកទឹក និងប្រព័ន្ធចែកចាយទឹកប្រកបដោយគុណភាព និងជឿទុកចិត្តបាន ដោយផ្អែកលើការសិក្សាប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ ដើម្បីធានាបាននូវការផ្គត់ផ្គង់ទឹកគ្រប់គ្រាន់ដល់ការប្រើប្រាស់ទឹកស្អាតប្រចាំថ្ងៃ និងសម្រាប់បម្រើឱ្យផលិតកម្មលើគ្រប់វិស័យ ក៏ដូចជាជួយដល់ការកាត់បន្ថយគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត

ទី៨៖ គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ត្រូវបន្តពង្រឹងកិច្ចសហការឱ្យបានកាន់តែមានប្រសិទ្ធភាពជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ព្រមទាំងជាមួយប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ ដៃគូសន្ទនា និងដៃគូអភិវឌ្ឍន៍ ដើម្បីសម្រេចឱ្យបានការអភិវឌ្ឍធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀតក្នុងអាងទន្លេមេគង្គកម្ពុជាប្រកបដោយនិរន្តរភាព និងភាពធន់ទៅនឹងអាកាសធាតុ

ទី៩៖ ត្រូវបន្តកិច្ចសហការឱ្យបានល្អជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបង្កើនកញ្ចប់ថវិកាសម្រាប់ការកសាង និងការជួសជុល-ថែទាំសំណង់ការងារទឹក និងជាមួយដៃគូអភិវឌ្ឍន៍ និងស្ថាប័នផ្តល់ជំនួយនានា ដើម្បីកៀរគរថវិកាសម្រាប់គាំទ្រដល់ការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍ ធនធានទឹក នៅកម្ពុជា។

***- ឯកឧត្តម លោកជំទាវ លោក លោកស្រី!***

ជាការពិត ការងារធនធានទឹក និងឧតុនិយមដែលត្រូវអនុវត្តបន្តមានច្រើន ប៉ុន្តែខ្ញុំមានជំនឿយ៉ាងមុតមាំថា ឈរលើសមិទ្ធផលនានាដែលយើងសម្រេចបាននាពេលកន្លងមក មេរៀន បទពិសោធន៍ និងការប្តេជ្ញាចិត្តរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់ ព្រមទាំងការចូលរួម និងកិច្ចសហការពីអ្នកពាក់ព័ន្ធ យើងនឹងបន្តសម្រេចបាននូវសមិទ្ធផលថ្មីៗបន្ថែមទៀត សំដៅធានាឱ្យបាននូវប្រភពទឹកស្អាតគ្រប់គ្រាន់សម្រាប់ផលិតកម្មគ្រប់វិស័យ ក៏ដូចជា ការចូលរួមទប់ស្កាត់ និងការកាត់បន្ថយនូវ គ្រោះមហន្តរាយធម្មជាតិនានា ដើម្បីជំរុញកំណើនសេដ្ឋកិច្ចជាតិឱ្យរីកចម្រើនកាន់តែឆាប់រហ័សថែមទៀត។

មុននឹងបញ្ចប់ ខ្ញុំសូមលើកទឹកចិត្តដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ បន្តខិតខំអនុវត្តអនុវត្តការងារឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីសម្រេចឱ្យបានជោគជ័យ លើគ្រប់ការងារដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួង ស្របតាមគោលដៅកំណត់។ ខ្ញុំក៏សូមអំពាវនាវដល់ក្រសួង-ស្ថាប័ន ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និងអ្នកពាក់ព័ន្ធទាំងអស់ បន្តផ្តល់ការគាំទ្រ និងកិច្ចសហការក្នុងភាពជាដៃគូពិតប្រាកដ ដល់ក្រសួង-ស្ថាប័នទាំង៣ ក្នុងការបំពេញបេសកកម្មរបស់ខ្លួន ឱ្យបានកាន់តែប្រសើរឡើងបន្ថែមទៀត។

ជាថ្មីម្តងទៀត ខ្ញុំសូមសម្តែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងធនធានទឹក និងឧតុនិយម គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និងអាជ្ញាធរទន្លេសាប ដែលបានខិតខំប្រឹងប្រែងយកអស់កម្លាំងកាយ កម្លាំងចិត្ត ប្រាជ្ញា ស្មារតី ក្នុងការបំពេញតួនាទីភារកិច្ចដ៏ថ្លៃថ្លានេះជូនជាតិ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួង-ស្ថាប័ន ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និងអ្នកពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមគាំទ្រ និងសហការដ៏ល្អ ជាកម្លាំងរួមដ៏រឹងមាំ ដើម្បីសម្រេចបាននូវការការពារធនធានទឹក និងការអភិវឌ្ឍធនធានទឹកប្រកបដោយចីរភាព សម្រាប់ប្រជាជនកម្ពុជាគ្រប់ៗរូប និងគ្រប់ជំនាន់។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរជ័យជូន ឯកឧត្តម លោកជំទាវ ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ ក៏ដូចជាសមាជិក សមាជិកាទាំងអស់នៃអង្គសន្និបាត សូមទទួលបាននូវសេចក្តីសុខ សេចក្តីចម្រើន ព្រមទាំង ប្រកបដោយពុទ្ធពរ និងពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងសម្រេចជោគជ័យក្នុងគ្រប់ភារកិច្ច នៅក្រោមម្លប់ដ៏ត្រជាក់នៃសុខសន្តិភាព។

តាំងនាមឱ្យ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជា-**ណាចក្រកម្ពុជា** ខ្ញុំសូមប្រកាសបិទ «សន្និបាតបូកសរុបលទ្ធផលការងារក្រសួងធនធានទឹក និងឧតុនិយម គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និងអាជ្ញាធរទន្លេសាប ប្រចាំឆ្នាំ២០២៤ និងទិសដៅអនុវត្តឆ្នាំ២០២៥» នាពេលនេះ៕

*សូមអរគុណ!*